## Saying “A moment please!”



នារី៖ លោកគ្រូ ខ្ញុំចង់រៀនបង្កើតតារាងក្នុងកុំព្យូទ័រ ធ្វើម៉េចទៅ លោកគ្រូ?
លោកគ្រូ៖ បង្កើតក្នុង Word បានតាស។
ចូល insert ហើយរើសចំនួនតារាងដែលនារីឯងចង់បង្កើតទៅបានហើយ។
នារី៖ ឈប់សិន លោកគ្រូ។ ខ្ញុំតាមអត់ទាន់អេ មួយៗ។ ដំបូងបើក Word មែន?
លោកគ្រូ៖ ហ្នឹងហើយ។
នារី៖ ខ្ញុំបើក Word ឲ្យចេញសិន ... អូខេ ចេញហើយ។ ហើយម៉េចទៀត លោកគ្រូ?
លោកគ្រូ៖ ចុច insert ហើយឃើញគេដាក់ថា table ។
នារី៖ កុំអាល លោកគ្រូ។ ចាំមើលណា រកមើលពាក្យ insert មែន លោកគ្រូ? នេះមែន?
លោកគ្រូ៖ ហ្នឹងហើយ។ ចុចវាទៅ ឃើញមានអីផ្សេងៗទៀតនៅក្រោមហ្នឹងហើយ។ ហើយរកមើលពាក្យ table រួចរើស ...
នារី៖ ចាំម៉ាភ្លែត លោកគ្រូ។ ខ្ញុំសុំរកពាក្យ table ឲ្យឃើញសិន។ ... អូខេ ឃើញហើយ។ ចុចលើវាមែន?
លោកគ្រូ៖ ចុចទៅ។ ហើយរើសតារាងដែលនារីឯងចង់បាន។ នារីឯងអូស mouse ក៏បាន ឬក៏ដាក់លេខយកម៉ងក៏បាន។ បើតារាងតិច អូស mouse ទៅលឿន តែបើតារាងច្រើន ទាល់តែបញ្ចូលលេខ ...
នារី៖ លោកគ្រូ ខ្ញុំសុំកាត់សិន។ កុំលឿនពេក ។ ខ្ញុំសុំសួរកន្លែងនេះមួយសិន ។
លោកគ្រូ៖ ចាំតិចណា ។ ខ្ញុំលើកទូរស័ព្ទមួយសិន។
នារី៖ ចាស។

| | |
|---|---|
| នារី | female Cambodian name |
| លោកគ្រូ | teacher; used to address a teacher |
| បង្កើតតារាង | to create a table (e.g., in a Word document) |
| ធ្វើម៉េចទៅ? | What to do? / How to do it? |
| រើស | to select, to choose |
| ឈប់សិន = ឈប់ៗ | a moment, please! |
| មួយៗ | one by one, one after the other |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ហើយម៉េចទៀត? | And what now? / Then? |
| ចុច | to press, to click |
| កុំអាល | a moment, please! / don't rush ...! |
| ចាំមើលណា | let me see ... |
| ចាំម៉ាភ្លែត = ចាំតិច | wait a moment! |
| សុំ ... សិនណា | Let me first ...! |
| អូស | to scroll, to pull |
| យកម៉ង | spoken form of យកតែម្ដង = directly |
| បញ្ចូលលេខ | to type in a number |
| ខ្ញុំសុំកាត់សិន | I'm sory to interrupt |
| សុំសួរកន្លែងនេះមួយសិន | May I ask [you] about this point first? |

## Cultural notes

របៀបនៃការធ្វើការងារឬធ្វើអ្វីមួយ មានភាពខុសគ្នាពីជនជាតិមួយទៅជនជាតិមួយ។ ជនជាតិជប៉ុនដែលមានទម្លាប់ធ្វើអ្វីលឿនៗ គឺមិនចូលចិត្តឲ្យគេចាំ ឬចាំគេនោះទេ។ ប៉ុន្តែ សម្រាប់ជនជាតិខ្មែរ នៅពេលដែលគេនិយាយថា "សូមចាំមួយភ្លែត" ពេលខ្លះត្រូវចាំយូរ ដោយសារសកម្មភាពរបស់ជនជាតិខ្មែរមានភាពយឺតយ៉ាវ។ នៅខ្មែរ អ្នកប្រហែលជានឹងឧស្សាហ៍ឮពាក្យថា ចាំមួយភ្លែត កុំអាល ឈប់សិន។

| | |
|---|---|
| របៀប | method, system, way to do sth. |
| មានភាពខុសគ្នា | to be different from each other |
| ទម្លាប់ | habit |
| ឲ្យគេចាំ | to make someone wait |
| ចាំគេ | to wait for someone |
| សកម្មភាព | activity, movement |
| ឧស្សាហ៍ឮ | to hear often |

## Additional dialogue

ប្អូនស្រី៖ បង!
បងស្រី៖ អីគេ? ចាំម៉ាភ្លែតណា។ ... អូខេ ម៉េចដែរ?
ប្អូនស្រី៖ បងជួយមើលតែងសេចក្ដីខ្ញុំតិចបានអេ? ក្រែងខុសពាក្យអង់គ្លេស។
បងស្រី៖ កុំអាលសិនបានអេ? ឥឡូវបងកំពុងរវល់។ ថ្ងៃណាត្រូវឲ្យគ្រូ?
ប្អូនស្រី៖ ថ្ងៃស្អែក។
បងស្រី៖ ចាំម៉ាភ្លែតសិនណា។ បងធ្វើការហើយ ចាំបងមើល។

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.